**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៩២២/១៧-៩-២០១២

សាលដីកា បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែល លេខ:៧២ក្រIV(ច)/៣១-១២-២០១២ប្រកាសអោយប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការ ជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី៣១-១២-២០១២ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៩២២ ចុះថ្ងៃទី១៧-៩-២០១២ រវាង:

-ជនជាប់ចោទឈ្មោះ [redacted] អើសហ៊ើត ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរប្រធានក្រុមហ៊ុន កើតនៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម ទីលំនៅមុនពេលកើតហេតុនៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted]រ) ម្តាយឈ្មោះ[redacted](ស) ប្រពន្ធឈ្មោះ[redacted]មានកូន០៥នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារម្តង។ ឃុំខ្លួនថ្ងៃទី06.02.២០១២

ជាប់ចោទពីបទ:មិនបំពេញកាតព្វកិច្ច ចំពោះឧបករណ៍អាចជួញដូរបាន និង រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០០៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់ និង មាត្រា៣៩១,៣៩២ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារលោក [redacted] សុគន្ធ

១





Scanned by CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភ័វុឌ្ឍ ភេទប្រុស ទីលំនៅបច្ចុប្បន្នផ្ទះលេខ៣៣៩០ ផ្លូវ១៧៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មេធាវីការពារលោក [redacted] វិសាល

តាមពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦.៧.២០១២ របស់ឈ្មោះ [redacted] ភ័វុឌ្ឍ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៤៩(ណ) ចុះថ្ងៃទី១០-៧-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

តាមពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០.៧.២០១២ របស់ឈ្មោ[redacted] អើសហ៊ើត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៤៩(ណ) ចុះថ្ងៃទី១០-៧-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី១ និង ទី២ នៃសេចក្តីសំរេចទាំងមូល ។

<u>ឯករឿងហេតុមានដូចតទៅ</u>

កាលពីអំឡុងខែមិថុនា ឆ្នាំ២០០៩ ឈ្មោះ [redacted] អើសហ៊ើត ភេទប្រុស អាយុ៤៣ឆ្នាំ បាននិយាយលួងលោមឲ្យឈ្មោះ [redacted] ភ័វុឌ្ឍ ប្រគល់ប្រាក់ចំនួន៥៣០០០$(ប្រាំម៉ឺនបីពាន់ដុល្លាអាមេរិក) នៅពេលនោះឈ្មោះ [redacted] ភ័វុឌ្ឍ មានការជឿទុកចិត្តក៏ព្រមប្រគល់ប្រាក់ ចំនួន៥៣០០០$(ប្រាំម៉ឺនបីពាន់ដុល្លាអាមេរិក) ទៅឲ្យឈ្មោះ [redacted] អើសហ៊ើត ហើយឈ្មោះនេះបានសរសេរមូលប្បទានប័ត្រចំនួន០២សន្លឹកឲ្យទៅឈ្មោះ [redacted] ភ័វុឌ្ឍ ប៉ុន្តែពេលឈ្មោ[redacted] ភ័វុឌ្ឍ យកមូលប្បទានប័ត្រទៅបើកប្រាក់នៅធនាគារ ហើយធនាគារបញ្ជាក់ថាគ្មានទឹកប្រាក់ទេ ។ បន្ទាប់មកនៅថ្ងៃទី២៨.០១.២០១១ ឈ្មោះ [redacted] អើសហ៊ើត ក៏បានមកនិយាយលួងលោមខ្ចីរថយន្តរបស់ឈ្មោ[redacted]ភ័វុឌ្ឍ ម៉ាក Mercedes S500 ផលិតឆ្នាំ២០០០ ដោយអះអាងថាយកទៅដឹកអ្នកវិនិយោគដែលមករកស៊ីក្នុងប្រទេសកម្ពុជា ក្រោយពីបានរថយន្តហើយឈ្មោ[redacted]អើសហ៊ើត បែរជាយករថយន្តទៅបញ្ចាំទៅវិញ ហើយបានប្រើល្បិចលួងលោមយកប្រាក់ពីឈ្មោះ [redacted] ភ័វុឌ្ឍ ជាបន្តបន្ទាប់ ដែលមានទឹកប្រាក់សរុបចំនួន១២៧.៥៦២,៥០$(មួយសែនពីរម៉ឺនប្រាំពីរពាន់ប្រាំមួយរយហុកសិបពីរដុល្លារអាមេរិក និង ហាសិបសេន)ទៀត ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ៤៩(ណ) ចុះថ្ងៃទី១០.៧.២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចខាងក្រោមៈ

១-ផ្តន្ទាទោសឈ្មោ[redacted] អើសហ៊ើត ភេទប្រុស អាយុ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៣ឆ្នាំ(បីមួយ) ពីបទៈមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និង រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០០៩ និងក្នុងឆ្នាំ២០១១ តាមមាត្រា

២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យឈ្មោះ [redacted] អើសហ៊ីត ផ្តល់សំណងថ្លៃចេញសែក ថ្លៃយកប្រាក់ទៅលស់យករថយន្ត និង ប្រាក់ជម្ងឺចិត្តសរុបចំនួន៤០០០០$(បួនម៉ឺនដុល្លារអាមេរិក) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាវុត្ថា ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣-វត្ថុចាប់យករួមមាន:

១/.ទូរស័ព្ទដៃចំនួន០២គ្រឿង ម៉ាកSamsung និងម៉ាក NoKia ។

២/.សៀវភៅគ្រួសារលេខ:១៧៧ ចំនួន០១ក្បាល ។

៣/.លិខិតឆ្លងដែនលេខ:០៥៣៧០១៣ ចំនួន០១ក្បាល ។

៤/.សៀវភៅធនាគារ Cambodia Public Bank លេខ:០៩១២៨១ ចំនួន០១ក្បាល ។

៥/.សែកធនាគារកម្ពុជាសាធារណ: ចំនួន០៣ក្បាល ។

៦/.លិខិតទិញលក់រថយន្ត ០៣សន្លឹក ។

៧/.រថយន្តមួយគ្រឿងម៉ាក RAV4 ពណ៌ទឹកមាស ពាក់ផ្លាកលេខ ភ្នំពេញ 2A 8558 ។

៨/.សែកធនាគារកាណាឌីយ៉ា ចុះថ្ងៃទី២៧.០១.២០១២ ដែលមានទឹកប្រាក់ចំនួន២៣០.000 USD (ម្ភៃបីម៉ឺនដុល្លារអាមេរិក) ចំនួន០១សន្លឹក ។

៩/.សែកធនាគារ May Bank ចំនួន០៤សន្លឹក មួយសន្លឹកមានទឹកប្រាក់ចំនួន១៧០០០០(ដប់ប្រាំពីរម៉ឺនដុល្លារអាមេរិក) ។

១០/.សែកធនាគារកម្ពុជាសាធារណ: ចុះថ្ងៃទី១២.០២.២០០៨ ដែលមានទឹកប្រាក់ចំនួន ៨០០០០USD(ប្រាំបីម៉ឺនដុល្លារអាមេរិក) ចំនួន០១សន្លឹក ។ តាមកំណត់ហេតុទទួលវត្ថុតាងលេខ:៩៤ អយក ចុះថ្ងៃទី៦.០២.២០១២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩.៦.២០១២ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី១០.៧.២០១២ ចំពោះមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខមេធាវីការពារជនជាប់ចោទ និង មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញរបាយការណ៍ចុះថ្ងៃទី០២.១១.២០១២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

-ប្រធានក្រុមប្រឹក្សាសម្រេចរឿងក្តី



Scanned by CamScanner

-ជនជាប់ចោទឈ្មោ[redacted] អើសហ៊ើត (វត្តមាន)

-មេធាវីការពារលោក[redacted] សុគន្ធ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]រ៉ាវុត្ថា (អវត្តមាន)

-មេធាវីការពារលោ[redacted] វិសាល (វត្តមាន)

-ឈ្មោះ [redacted] អើសហ៊ើត ឆ្លើយថា: សែកមិនមែនជារបស់ខ្លួនទេ គឺរបស់ក្រុមហ៊ុន ទាល់តែមានប័ណ្ណប៉ាតង់ទើបអាចបើកសែកបាន ។ ពេលខ្លួនចេញមិនទាន់មានលុយទេ ហើយក៏មិនទាន់ដាក់ថ្ងៃខែដែរ ។ ខ្លួនខ្ចីគាត់បីពាន់ដុល្លាទៅម៉ាឡេស៊ី ការខ្ចីគឺមុនចេញសែក ។ ខ្លួនជំពាក់ទាំងអស់៤៤០០$ អាមេរិក ខ្លួនបានសងលុយគាត់អស់ហើយ ដោយមិនបានយកសែកទៅវិញទេ ។ ខ្លួនចេញសែកឱ្យគាត់ទៅឆ្នាំ២០០៩ គាត់សរសេរដាក់ដោយខ្លួនគាត់ គាត់រៀបចំដើម្បីខ្លួនជាប់គុក ។ ឡាននោះគឺឈ្មោះខ្លួនទាំងអស់ ពេលនោះខ្លួនឱ្យទៅលោះយកមក ហើយគាត់យកមកដាក់ឈ្មោះគាត់ ។ អ្នកបើកបរមិនដឹងថាជារបស់អ្នកណាទេ ខ្លួនទៅលោះដោយទារលុយគាត់ពាក់កណ្តាល និង លុយខ្លួនពាក់កណ្តាល ។

សំណូមពរសូមក្រុមប្រឹក្សារកយុត្តិធម៌ឱ្យរូបខ្លួនផង ។

-មេធាវីលោក [redacted] វិសាល ការពារសិទ្ធិឱ្យដើមបណ្តឹងសន្និដ្ឋានថា: កូនក្តីខ្លួនប្តឹងពីរឿងសំណង និង ទោស ពាក់ព័ន្ធរឿងឡានគឺឡានជារបស់កូនក្តីខ្លួន គាត់បានខ្ចីឡានកូនក្តីខ្លួនដឹកភ្ញៀវ ហើយយកទៅបញ្ចាំកាស៊ីណូ ។ ការចេញសែកមិនមានទឹកប្រាក់ ឡានក៏យកទៅបញ្ចាំនៅណាហ្គា គាត់បានខ្ចីលុយកូនក្តីខ្លួនចំនួន១០ម៉ឺនដុល្លាអាមេរិក ជនជាប់ចោទនេះចេញសែកគ្មានសាច់ប្រាក់ និង រំលោភលើទំនុកចិត្ត ។

សំណូមពរសូមក្រុមប្រឹក្សាតម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃទី១០-៧-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដដែល ។

-មេធាវីលោក [redacted] សុគន្ធ ការពារសិទ្ធិឱ្យជនជាប់ចោទសន្និដ្ឋានថា: ដែលចាត់ទុកជាមូលប្បទានប័ត្រទាល់តែមានកាលបរិច្ឆេទត្រឹមត្រូវ ។ សែកនេះកូនក្តីខ្លួនបានចេញឱ្យ[redacted]រ៉ាវុត្ថា នេះគឺមិនដាក់ថ្ងៃខែទេ ។ សែកនេះកូនក្តីខ្លួនចេញតាំងពីឆ្នាំ២០០៩ ឯគាត់មានទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងការទុកចិត្តគ្នា ។ ចំពោះឡានដែលយកទៅលោះលើកទី២ គឺជាតម្លៃរបស់គាត់ ឯសែកគឺរបស់សុពលភាពហើយ ។

សំណូមពរសុំបដិសេធសាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃទី១០-៧-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលដាក់ទោសកូនក្តីខ្លួនចំនួន៣ឆ្នាំ ចោលជាអសារបង់ ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: ក្រោយពីបានស្តាប់របាយការណ៍ និង ក្រោយពីបានស្តាប់សន្និដ្ឋានរបស់លោកមេធាវីទាំងសងខាង សូមក្រុមប្រឹក្សាតម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃទី១០-៧-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។



Scanned by CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

**យល់ឃើញថា:**

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-៧-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] អើសហ៊ើត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃទី១០-៧-២០១២ ត្រង់ចំណុចទី១ និងទី២ នៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

-សេចក្តីចម្លងពាក្យបណ្តឹងឧទ្ធរណ៍លេខ:៨៨៩ ចុះថ្ងៃទី២៦-៧-២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ាវុឌ្ឍ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃទី១០-៧-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២-នាពេលសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ [redacted] អើសហ៊ើត បានទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ពីឈ្មោ[redacted] រ៉ាវុឌ្ឍ ចំនួនពីរលើក គឺម្តងខ្ចី៣០០០$ និង ម្តងទៀតខ្ចី ១៤០០$ ក្រោយមកខ្លួនបានចេញមូលប្បទានប័ត្រ២សន្លឹក ដើម្បីសងទៅ [redacted] រ៉ាវុឌ្ឍ វិញ មូលប្បទានប័ត្រនោះមិនទាន់អាចបើកលុយបានទេ ពីព្រោះគ្មានលុយក្នុងគណនីធនាគារទេ ហើយខ្លួនមិនទាន់ចុះកាលបរិច្ឆេទនៅលើមូលប្បទានប័ត្រទេ ។ ជនជាប់ចោទបានសារភាពយ៉ាងច្បាស់ថា ខ្លួនខ្ចីលុយមុនរួចទើបចេញមូលប្បទានប័ត្រសងជាក្រោយ ។ ការសារភាពរបស់ជនជាប់ចោទបង្ហាញឲ្យឃើញពីចេតនាទុច្ចរិត ពីព្រោះខ្លួនបានដឹងហើយថាមូលប្បទានប័ត្រនោះគ្មានលុយក្នុងគណនីគ្រប់គ្រាន់ទេ នៅតែចេញមូលប្បទានប័ត្រឲ្យដើមបណ្តឹ[redacted] រ៉ាវុឌ្ឍ ទៅបើកប្រាក់ទៀត ។

៣-ចំពោះការឆ្លើយដោះសាររបស់ជនជាប់ចោទថា: មូលប្បទានប័ត្រដែលខ្លួនចេញនោះគ្មានចុះកាលបរិច្ឆេទដែលត្រូវបើកនោះ ឃើញថាគ្មានភស្តុតាងឲ្យតុលាការជឿបានទេ ពីព្រោះតាមភស្តុតាងជាមូលប្បទានប័ត្រលេខ:១០-៥០១២-១ មានការចុះកាលបរិច្ឆេទត្រឹមត្រូវនៅថ្ងៃទី០២.១១.២០១១ ។ រីឯការ



Scanned by CamScanner

ឆ្លើយបំភ្លឺថាខ្លួនបានសងប្រាក់ដែលជំពាក់នោះទៅឱ្យដើមបណ្តឹង [redacted] ភាំវុឌ្ឍ ហើយនោះ គឺជាការសង ក្រោយពេលចេញមូលប្បទានប័ត្រ និង ក្រោយពេលដែលដើមបណ្តឹងបានទៅបើកប្រាក់មិនបាន តាមមូលប្បទានប័ត្រនោះ ។ ប៉ុន្តែការអះអាងការសងប្រាក់ជំពាក់នេះក៏គ្មានភស្តុតាងជាឯកសារថា ដើមបណ្តឹងបានទទួលការសងដែរ ហើយដើមបណ្តឹងក៏បានបដិសេធហើយដែរ ។ ក្រុមប្រឹក្សាយល់ថា ទោះជាមានការសង ឬ មិនបានសងប្រាក់ជំពាក់ខាងលើក៏ដោយ ក៏អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានប្រព្រឹត្តរួចទៅហើយ ពោលគឺបានចេញមូលប្បទានប័ត្រដោយគ្មានទឹកប្រាក់ក្នុងគណនី ដើម្បីសងទៅ[redacted]ាំវុឌ្ឍ ដោយចេតនាទុច្ចរិត ។

៤-ជនជាប់ចោទក៏បានទទួលស្គាល់នាពេលសវនាការថា ខ្លួនពិតជាបានយករថយន្តម៉ាក Mercedes S500 ស៊េរី២០០០ យកទៅដាក់បញ្ចាំមែន ។ ប៉ុន្តែជនជាប់ចោទបានឆ្លើយដោះសារថា: រថយន្ត Mercedes នេះ ជាសហកម្មសិទ្ធិជាមួយខ្លួន ព្រោះរថយន្តនេះបានមកពីការរត់ការឱ្យក្រុមហ៊ុន ស៊ុនទ្រី រួចបានថ្លៃកំរៃជើងសារជារថយន្តនេះ ។ ការឆ្លើយថាជាកម្មសិទ្ធិរួមរវាងខ្លួនជាមួយ[redacted]ាំវុឌ្ឍ នេះ ឃើញ ថា គ្មានភស្តុតាងបង្ហាញថាជាសហកម្មសិទ្ធិលើរថយន្ត Mercedes នេះទេ ផ្ទុយទៅវិញមានជាឯកសារ ភស្តុតាងថាជារថយន្តរបស់[redacted] ភាំវុឌ្ឍ ។ ក្រុមប្រឹក្សាយល់ថា ទោះជារថយន្តនេះជាសហកម្មសិទ្ធិរួមជា មួយដើមចោទ[redacted] ភាំវុឌ្ឍ ក៏ដោយ ក៏ឈ្មោះ អាប់ទុលឡាទីហ្វ គ្មានសិទ្ធិយកទៅដាក់បញ្ចាំដោយឯកតោភាគីទេ គឺត្រូវមានការយល់ព្រមពីឈ្មោះ [redacted] ភាំវុឌ្ឍ ដែរ ។ ហេតុនេះឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តិអំពើរំលោភលើទំនុកចិត្ត ពិតប្រាកដមែន ។

៥-ក្រៅពីសំអាងហេតុខាងលើ សាលាឧទ្ធរណ៍ឯកភាពទាំងស្រុង លើសំអាងហេតុដែលមានក្នុងសាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃទី១០.៧.២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៦-សាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃ១០.៧.២០១២ របស់សាលាដំបូង បានសម្រេចមកត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-៧-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] អើសហ៊ីត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-៧-២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភាំវុឌ្ឍ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៤៩(ណ) ចុះថ្ងៃទី១០.៧.២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។



Scanned by CamScanner

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និង មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា[redacted] | ហត្ថលេខា[redacted] | ហត្ថលេខា[redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]